ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
# ក្នុងវិស័យអប់រំ
# ២០០៦-២០១០

ខែ តុលា ឆ្នាំ ២០០៦

រៀបចំដោយក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួងអប់រំ យុវជន និង

កីឡា

សហការជាមួយអង្គការ យូនីសេហ្វ

unicef

# មាតិការឿង

ទំព័រ


អារម្ភកថា---------------------------------------------------------- i

សេចក្តីថ្លែងអំណរគុណ---------------------------------------------------------- ii

I-សេចក្តីផ្តើម---------------------------------------------------------- ១

II-ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ---------------------------------------------------------- ២

ក.វត្ថុបំណងជាក់លាក់---------------------------------------------------------- ២

ខ.បញ្ហាទូទៅ---------------------------------------------------------- ២

គ.សំណើជាគន្លឹះពិសេសនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០---------- ៧

ឃ.ការឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍ដើម្បីលើកកម្ពស់ សមភាព សមធម៌យេនឌ័រក្នុង
ការអប់រំ---------------------------------------------------------- ៧

ង.ការគាំទ្រផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ---------------------------------------------------------- ៨

ច.ឧបសគ្គ និងការសន្ទួតនៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ---------------------------------------------------------- ៩

ឆ.ក្របខ័ណ្ឌសមហេតុផលនៃកម្មវិធីបញ្ជ្រាបយេនឌ័រ---------------------------------------------------------- ១០

លទ្ធផលដំបូងទី ១---------------------------------------------------------- ១១

លទ្ធផលដំបូងទី ២---------------------------------------------------------- ១៥

ឧបសម្ព័ន្ធ ក

ផែនការការងារសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា លើការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០---------------------------------------------------------- ១៩

ឧបសម្ព័ន្ធ ខ

គោលដៅសម្រាប់ការបញ្ជ្រាបយេនឌ័រ ២០០៦-២០១០---------------------------------------------------------- ២៩

# អារម្ភកថា

រាជរដ្ឋាភិបាល បានចាត់ទុកការអប់រំជាយុទ្ធសាស្ត្រចម្បងក្នុងការកាត់បន្ថយភាពក្រីក្រ ដូចដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ឈរលើយុទ្ធសាស្ត្រចតុកោណសម្រាប់ការជំរុញកំណើនការបង្កើតការងារ ការធានាសមធម៌ និងប្រសិទ្ធភាព ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការអប់រំសម្រាប់ទាំងអស់គ្នា ដោយមានការតម្រង់ទិសច្បាស់លាស់សម្រាប់ពេលអនាគត និងមានចរិតគាំទ្រប្រជាជនក្រីក្រ និងការអភិវឌ្ឍជនបទ ។ ដើម្បីឆ្លើយតបទៅនឹងគោលដៅ និងយុទ្ធសាស្ត្រខាងលើក្រសួងអប់រំ យុវជន និង កីឡា បានកសាងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥ ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០០៦-២០១០ និងផែនការគាំទ្រវិស័យអប់រំ ២០០៦-២០១០ ដែលមានលក្ខណៈជាកម្មវិធីប្រាំឆ្នាំរំកិលសម្រាប់បំពេញបន្ថែមឱ្យមានលក្ខណៈប្រតិបត្តិ និងជាក់ស្តែង ។

ក្រសួងអប់រំ យុវជន និង កីឡា កំណត់ច្បាស់ថាការអប់រំ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ធានាសមភាព និងការផ្តល់អំណាចស្ត្រី ។ សារសំខាន់នៃការលុបបំបាត់គម្លាតយេនឌ័រគឺត្រូវខិតខំអនុវត្តឱ្យបានល្អនូវការចុះឈ្មោះចូលរៀនរបស់សិស្ស ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីសិក្សា និងលំនាំនៃការសិក្សា ដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អ និងបញ្ចប់ការសិក្សាដោយជោគជ័យនៅក្នុងប្រព័ន្ធអប់រំទាំងមូល ។ ប្រការនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការអនុវត្តគោលការណ៍សមធម៌ក្នុងការចូលរៀន ពោលគឺការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជាពិសេសសិស្សស្រី ការកសាងអន្តេវាសិកដ្ឋានសម្រាប់សិស្ស គរុសិស្ស និងនិស្សិតស្ត្រី ។ ការកសាងអគារសិក្សា និងការបង្កើតអនុវិទ្យាល័យលើមូលដ្ឋានសាលាបឋមសិក្សាដែលមានស្រាប់ ដោយបន្ថែមគ្រូ និងបន្ទប់រៀនបានផ្តល់ឱកាសឱ្យសិស្សស្រីបានរៀនបន្ត និងបញ្ចប់ការសិក្សាយ៉ាងតិច ៩ ឆ្នាំ និងខ្ពស់ជាង ។ ក្នុងការលើកកម្ពស់សមត្ថភាព និងតួនាទីរបស់ស្ត្រី ក្រសួងអប់រំ យុវជន និង កីឡា បានបើកវគ្គបណ្តុះបណ្តាល និងបំប៉ន លើជំនាញរដ្ឋបាល គ្រប់គ្រង ការយល់ដឹងពីយេនឌ័រការបញ្ជ្រាបយេនឌ័រទៅក្នុងការអភិវឌ្ឍគោលនយោបាយ ផែនការ និងកម្មវិធីនានា ។ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០០៦-២០១០ គឺជាផែនការមួយសម្រាប់ជួយបំពេញផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្ពោះទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅឆ្នាំ២០១៥ ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងជួយគាំទ្រ និងរួមសហការដើម្បីអនុវត្តផែនការនេះឱ្យសម្រេចដោយជោគជ័យ ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**បណ្ឌិត កុល ផេង**

# សេចក្តីថ្លែងអំណរគុណ

សមិទ្ធផល " ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០០៦-២០១០" គឺជាស្នាដៃរបស់ក្រុមការងារយេនឌ័រនៃក្រសួងអប់រំ យុវជន និង កីឡា ឧបត្ថម្ភដោយអង្គការ UNICEF ។

សមាជិកក្រុមការងារយេនឌ័រទាំងអស់ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះឯកឧត្តមថ្នាក់ដឹកនាំក្រសួងដែលជានិច្ចកាលជួយគាំទ្រ លើកទឹកចិត្ត ព្រមទាំងផ្តល់ភាពកក់ក្តៅដល់ក្រុមការងារដែលធ្វើឱ្យយើងខ្ញុំមានកម្លាំងចិត្តខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គ កសាងបាននូវស្នាដៃដ៏ប្រពៃនេះ ។

សូមថ្លែងអំណរគុណដល់អង្គការ UNICEF អង្គការ UNESCO និងដៃគូអភិវឌ្ឍន៍ដែលបានជួយឧបត្ថម្ភផ្នែកសម្ភារ បច្ចេកទេស និងថវិកាដល់ក្រុមការងារក្នុងការធ្វើឱ្យសម្រេចស្នាដៃដ៏វិសេសវិសាលនេះ ។

សូមឱ្យការប្តេជ្ញាចិត្តរបស់អ្នកពាក់ព័ន្ធទាំងអស់ ប្រែក្លាយទៅជាសកម្មភាពអនុវត្តជាក់ស្តែងដើម្បីសម្រេចសមធម៌ និងសមភាពយេនឌ័រ ។

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ
# ២០០៦-២០១០

# I-សេចក្តីផ្តើម

ការបញ្ជ្រាបយេនឌ័រត្រូវផ្អែកលើការយល់ឃើញថា រចនាសម្ព័ន្ធ វប្បធម៌ និងការអនុវត្តរបស់អង្គភាពនឹងត្រូវបានប្រែក្លាយទៅជាការបង្កើតបរិស្ថានមួយដែលនាំឱ្យមានសមភាព និងសមធម៌យេនឌ័រ។ ការផ្លាស់ប្តូររបស់អង្គភាពបានជួយធ្វើឱ្យមានការយកចិត្តទុកដាក់ខ្លាំងចំពោះបញ្ហាយេនឌ័រ។ ប្រការនេះមានន័យថាការបង្កើតគោលនយោបាយនិងផែនការសកម្មភាពនឹងជួយធ្វើឱ្យដំណើរការអង្គភាពមានការផ្លាស់ប្តូរ។នេះគឺជាយុទ្ធសាស្ត្រសម្រាប់ដោះស្រាយកង្វល់របស់បុរសនិងស្ត្រីដើម្បីទទួលបានផលចំណេញស្មើគ្នា និងលុបបំបាត់វិសមភាពក្នុងការរៀបចំការអនុវត្តការពិនិត្យតាមដាន និងការវាយតម្លៃលើគោលនយោបាយ និងកម្មវិធីគ្រប់ជ្រុងជ្រោយ។ ការបញ្ជ្រាបយេនឌ័រតម្រូវឱ្យមានសកម្មភាពផ្លាស់ប្តូរឥរិយាបថនិងដករបាំងដែលរារាំងការចូលរួមរបស់ស្ត្រីចេញ។ មូលដ្ឋានសំខាន់នៃបញ្ហានេះគឺការកែប្រែឥរិយាបថដែលមិនឱ្យស្ត្រីចូលរួមជាដៃគូស្មើភាព។

ចំណុចសំខាន់នៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះគឺបានឆ្លើយតបទៅនឹងវប្បធម៌អប់រំរបស់អង្គភាពនៅក្នុងក្រសួងអប់រំ យុវជន និង កីឡា ។ ការកសាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០ ជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាដោយអនុលោមតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ វេទិកាក្រុងដាកាស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា វេទិកា **ក្រុងប៉េកាំង** សម្រាប់សកម្មភាព និង អនុសញ្ញាសម្រាប់ការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងស្ត្រីភេទ។ អនុសញ្ញាអន្តរជាតិទាំងអស់នេះធានាសិទ្ធិស្មើគ្នារបស់ស្ត្រី និងកុមារីក្នុងការអប់រំ និងជួយជំរុញការលុបបំបាត់ការរើសអើងស្ត្រី និងកុមារីក្នុងវិស័យអប់រំ និងក្នុងវង្វង់នៃជីវិត ។

គោលដៅជាក់លាក់ស្តីពីសមភាពយេនឌ័រមានចែងនៅក្នុងការអប់រំសម្រាប់ទាំងអស់គ្នាហើយធ្វើជាចំណុចប្រមូលផ្តុំសម្រាប់សកម្មភាពជាតិនោះគឺ :

**គោលដៅទី២** : ធានាថានៅឆ្នាំ ២០១៥ កុមារទាំងអស់ជាពិសេសកុមារី និងកុមារស្ថិតនៅក្នុងស្ថានភាពលំបាក និងជនជាតិភាគតិចត្រូវបានប្រមូលឱ្យចូលរៀន និងបំពេញការសិក្សាដោយឥតបង់ថ្លៃ និងប្រកបដោយគុណភាព។

**គោលដៅទី៥** : លុបបំបាត់គម្លាតយេនឌ័រនៅក្នុងបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ ២០០៥ និងធ្វើឱ្យបានសម្រេចនូវសមភាពយេនឌ័រក្នុងវិស័យអប់រំនៅឆ្នាំ ២០១៥ ដោយផ្តោតលើការយកចិត្តទុកដាក់ធានាឱ្យកុមារីបានទទួលលទ្ធភាពចូលរៀនដោយពេញលេញ និង ស្មើភាពនិងសម្រេចបានការអប់រំមូលដ្ឋានប្រកបដោយគុណភាព។

គោលដៅទាំងនេះត្រូវបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ដែលមានគោលនយោបាយជាអាទិភាពដូចខាងក្រោម ÷

១.ធានាការទទួលបានការអប់រំដោយសមធម៌

២.លើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ

៣.អភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់វិមជ្ឈការ ។

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរួមបញ្ចូលគ្នាជាប្រព័ន្ធ និងគ្របដណ្តប់លើគ្រប់ផ្នែកនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ។ យេនឌ័រជាបញ្ហា និងជាយុទ្ធសាស្ត្រប្រទាក់ក្រឡានៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ។

## II-ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០

### គោលដៅ និងវត្ថុបំណង

គោលដៅនៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០ គឺជាការធានាការចូលរៀនដោយស្មើភាពគ្នា និងពេញលេញដើម្បីសម្រេចលទ្ធផលសិក្សានៅកម្រិតអប់រំមូលដ្ឋានប្រកបដោយគុណភាពដូចបានបញ្ជាក់នៅក្នុងគោលដៅទី ៥ នៃការអប់រំសម្រាប់ទាំងអស់គ្នា។ ប្រការនេះមានសារសំខាន់ណាស់ដើម្បីកំណត់ការយកចិត្តទុកដាក់ទៅលើការអប់រំមូលដ្ឋានប្រកបដោយគុណភាពល្អ ។ ការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ គឺជាយុទ្ធសាស្ត្រមួយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ។

### ក.វត្ថុបំណងជាក់លាក់មាន ÷

១.បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅគ្រប់កម្រិត ។

២.បង្កលក្ខណៈងាយស្រួលដល់ការរៀបចំឥរិយាបថសង្គមវិជ្ជមាន និងលើកតម្លៃការអប់រំរបស់កុមារី និងដៃគូស្មើភាពរវាងបុរស និងស្ត្រីនៅក្នុងសង្គមកម្ពុជា ជាពិសេសនៅក្នុងចំណោមអ្នកដឹកនាំសហគមន៍ មាតាបិតា និងបុរស ។

វត្ថុបំណងនៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០ ឆ្លើយតបនឹងគោលដៅអភិវឌ្ឍសហសវត្សរ៍កម្ពុជាទី ២ ដែលធ្វើឱ្យសម្រេចបានការអប់រំមូលដ្ឋាន៩ ឆ្នាំ គួបផ្សំនឹងនឹងចំណុចដៅទាំង ៣ នោះគឺ ÷

១.ការធានាថាកុមារទាំងអស់បានចូលរៀននៅបឋមសិក្សានៅឆ្នាំ ២០១០ និងអប់រំមូលដ្ឋាននៅឆ្នាំ ២០១៥

២.ការលុបបំបាត់វិសមភាព យេនឌ័រនៅក្នុងការអប់រំមូលដ្ឋាន ៩ ឆ្នាំនៅឆ្នាំ ២០១០ និង

៣.ការកាត់បន្ថយវិសមភាព និងគម្លាតយេនឌ័ររវាងទីក្រុង និងជនបទនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

### ខ.បញ្ហានានា

នៅក្នុងឆ្នាំ ២០០៦ ក្រសួងអប់រំ យុវជន និង កីឡា បានវាយតម្លៃពីជោគជ័យនៃការបង្កើនការអប់រំកុមារី និង សមភាពយេនឌ័រដែលបានជួយសម្រួលដល់ការចូលរៀននៅបឋមសិក្សារបស់ក្មេងស្រីព្រមទាំងបានដាក់ចេញមូលដ្ឋានសកម្មភាពរយៈពេលវែងដើម្បីរក្សាក្មេងស្រីឱ្យនៅក្នុងប្រព័ន្ធអប់រំ ។ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០ បានកសាងឡើងដោយផ្អែកលើផលទទួលបាននិងការខ្វះចន្លោះនៃការខិតខំប្រឹងប្រែង ពីមុនលើការ បញ្ជ្រាបយេនឌ័រនៅក្នុងវិស័យអប់រំ ។

**ផលទទួលបានពីការបញ្ជ្រាបយេនឌ័រឆ្នាំ ២០០២-២០០៦**

មុនឆ្នាំ ២០០២ អត្រាចុះឈ្មោះចូលរៀនក្មេងស្រីនៅមានកម្រិតទាបនៅឡើយ ។ ការចូលរៀននៅតែជាការប្រឈមមុខមួយ ។ បច្ចុប្បន្ននេះក្មេងស្រីជាច្រើនបានចូលរៀននៅបឋមសិក្សា ។ការប្រឈមនៅតែមានជាបន្តបន្ទាប់ដោយក្មេងស្រីបោះបង់ការសិក្សាច្រើននៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ។អត្រាគង់វង្សនៅថ្នាក់ទី ៥ និងអត្រាឆ្លងភូមិ សិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិនៅមានកម្រិតទាបក្នុងចំណោមសិស្សស្រី ។

អន្តរាគមន៍ផ្ទាល់ និងវិធានការវិជ្ជមានបានធ្វើឡើងដើម្បីបង្កើនការអប់រំ និងសមភាពយេនឌ័រសម្រាប់ក្មេងស្រីដែលមានលក្ខណៈត្រឹមត្រូវនោះគឺ ការកសាងអន្តេវាសិកដ្ឋានដែលបាននិងកំពុងដំណើរការកម្មវិធីអាហារូបករណ៍ដែលបាននិងកំពុងអនុវត្ត ។

ការបង្ហាញលំអិតពីលទ្ធផលនៃការបញ្ជ្រាបយេនឌ័រក្នុងអំឡុងពេលអភិវឌ្ឍន៍លើកមុន មាននៅក្នុងរបាយការណ៍ស្តីពីការពិនិត្យតាមដាន ការរីកចម្រើនលើការបញ្ជ្រាបយេនឌ័រ ២០០២-២០០៦ ។

**ដំណាក់កាលសំខាន់មួយនៃការបញ្ជ្រាបយេនឌ័រ នៅក្នុងការអប់រំស្ថិតនៅក្នុងការខិតខំប្រឹងប្រែងសម្រាប់ការរីកចម្រើនដើម្បីកសាងសមត្ថភាពថ្នាក់ជាតិ លើកកម្ពស់ការអប់រំកុមារី និងសមភាពយេនឌ័រ ។**

ទោះបីដំណើរការមិនទាន់សម្រេចបានពេញលេញនិងទូលំទូលាយយ៉ាងណាក៏ដោយ ក៏យើងនៅបានទទួលផលមួយចំនួនគួរឱ្យកត់សម្គាល់ដែរ ។ ក្រសួង អប់រំ យុវជន និង កីឡា បាន :

១-ដាក់ចេញមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយយេនឌ័រ ។

២-បង្កើតរចនាសម្ព័ន្ធយេនឌ័រនៅក្នុងក្រសួងអប់រំ យុវជន និង កីឡាសម្រាប់ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ។

៣-បង្កើនការយល់ដឹងពីការបញ្ជ្រាបយេនឌ័រ ។

៤-កសាងសមត្ថភាពមន្ត្រីថ្នាក់ជាតិមួយចំនួន ដើម្បីបំពេញការងារបញ្ជ្រាបយេនឌ័រ ។

៥-បង្កើតស្ថិតិយេនឌ័រសំខាន់ៗ សម្រាប់ធ្វើផែនការ និងពិនិត្យតាមដានការអនុវត្តគោលនយោបាយ និងផលប៉ះពាល់ ។

៦-បង្កើតភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនឹងវិស័យមួយចំនួន រួមមានវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាលដែលបានផ្តួចផ្តើមឡើងនិងបណ្តាញគាំទ្រសម្រាប់ការលើកកម្ពស់ការអប់រំកុមារីនិងសមភាពយេនឌ័រ ។

ដំណើរការបញ្ជ្រាបយេនឌ័របានចាប់ផ្តើម រីឯលទ្ធផលត្រូវបានធ្វើការពិនិត្យតាមដានជាប់ជាប្រចាំ ។ សកម្ម ភាពបានចាប់ផ្តើមនៅថ្នាក់ក្រសួងដែលមានជាអាទិ៍ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីគាំទ្រវិស័យអប់រំ ។ ផលទទួលបានជាមធ្យមខ្លះត្រូវធ្លាក់ចុះ ប៉ុន្តែសកម្មភាពជាច្រើនទាមទារឱ្យអនុវត្តដើម្បីធានានិរន្តរភាពកម្មវិធី និងផលទទួលបានព្រមទាំងធានាថានឹងកើតមានឡើងនៅថ្នាក់ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងសាលារៀន ។

សកម្មភាពមួយនៃកម្រងសិក្ខាសាលាយេនឌ័រក្នុងឆមាសទី១ ឆ្នាំ២០០៦ បានបញ្ជាក់ពីដំណើរការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យអប់រំដែលកំពុងប្រព្រឹត្តទៅជាបន្តបន្ទាប់ ។

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបន្តការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំកំពូលជាប្រចាំដើម្បីសម្រេចចំណុចដៅនេះ ។ ការបន្តខិតខំប្រឹងប្រែងគឺជាការអនុវត្តគោលនយោបាយ ជាពិសេសនៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ។

**ការខ្វះចន្លោះនៅក្នុងការបញ្ជ្រាបយេនឌ័រ**

ចំពោះលទ្ធផលអប់រំ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សាជាបញ្ហាដែលត្រូវពិចារណាក្នុងទសវត្សរ៍ខាងមុខ ។ ការផ្តល់សេវាអប់រំ និងសម្ភារបរិក្ខាជាលក្ខខណ្ឌដំបូងដើម្បីជំរុញការប្រមូលក្មេងស្រីឱ្យចូលរៀនបានច្រើននៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ។

ទីតាំងភូមិសាស្ត្រដូចជា ទីក្រុង ជនបទ និងតំបន់ដាច់ស្រយាល ជាកត្តាសំខាន់នៅ ក្នុងយុទ្ធនាការសម្រាប់ការអប់រំ កុមារី ។តំបន់ដាច់ស្រយាលនៃទីតាំងភូមិសាស្ត្រ ធ្វើឱ្យក្មេងស្រីជួបការលំបាកខ្លាំង ព្រោះសាលាថ្នាក់រៀន គ្រូបង្រៀន សម្ភារបង្រៀនមានការខ្វះខាត អាស្រ័យដោយភាពក្រីក្រនៅតំបន់នោះ ។ តាមពិតដំណោះស្រាយបញ្ហានេះក្រសួងអប់រំ យុវជន និង កីឡាម្នាក់ឯងមិនអាចសម្រេចបានទេ។ ប្រការនេះត្រូវទាមទារឱ្យមានការជួយជ្រោមជ្រែងពីសំណាក់អ្នកពាក់ព័ន្ធផ្សេងៗទៀតតាមរយៈការតស៊ូមតិ និង ការបង្កើតបណ្តាញគាំទ្រ។

ការកសាងសមត្ថភាពថ្នាក់ជាតិ នៅតែជាតម្រូវការ និងជាការប្រឈមនៅឆ្នាំបន្តបន្ទាប់ ។ ថ្វីត្បិតតែការយល់ដឹង ចំណេះដឹង និងបំណិនបានលើកឡើង និងបានកសាងនៅកម្រិតថ្នាក់កណ្តាល ប៉ុន្តែក្រសួងអប់រំ យុវជន និង កីឡា ចាំបាច់ត្រូវផ្សព្វផ្សាយឱ្យទៅដល់សាលារៀន ឃុំ-សង្កាត់ ទាំង ២៤ខេត្ត-ក្រុង ។ នេះជាការខ្វះចន្លោះដែលត្រូវយកចិត្តទុកដាក់នៅក្នុងដំណើរការបញ្ជ្រាបយេនឌ័រលើកក្រោយ ព្រោះថាការធ្វើឱ្យសម្រេចការបញ្ជ្រាបយេនឌ័រជាក់ស្តែង គឺអាចកើតមានល្អបំផុតនៅថ្នាក់ ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងសាលារៀន ។ ការផ្តល់សារសំខាន់លើការកសាងសមត្ថភាពបញ្ជ្រាបយេនឌ័រថ្នាក់មូលដ្ឋាន ជាកម្លាំងជំរុញមួយសម្រាប់ការបញ្ជ្រាបយេនឌ័រ ២០០៦-២០១០ ។

សមត្ថភាពថ្នាក់ជាតិត្រូវបានកសាងឡើងសម្រាប់ធ្វើជាចំណុចប្រមូលផ្តុំការប្តេជ្ញាចិត្ត សមត្ថភាពគាំទ្រយេនឌ័រ និងអ្នកអប់រំបញ្ហាយេនឌ័រ (រួមមានបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន) ដែលជាអ្នកបញ្ចូលសកម្មភាពទៅក្នុងគោលនយោបាយយេនឌ័រនិងសកម្មភាពវិជ្ជមានផ្សេងទៀត។ប្រការនេះអាចធ្វើឱ្យមានស្ត្រីច្រើននៅក្នុងចំណោមនាយកសាលា និងនាយករង មន្ត្រីថ្នាក់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ការិយាល័យ អប់រំ យុវជន និង កីឡា ស្រុក-ខណ្ឌ និងអាច មានស្ត្រីក្នុងតំណែងខ្ពស់នៅថ្នាក់កណ្តាល ។ អ្នកទាំងនេះត្រូវបានចាត់ទុកជាតួអង្គសំខាន់ក្នុងការរៀបចំឱ្យមានបរិស្ថានបញ្ជ្រាបយេនឌ័រក្នុងប្រព័ន្ធអប់រំ ។

**ចំណុចសំខាន់នៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០០៦-២០១០**

**យុទ្ធសាស្ត្រទី ១ :** ចំពោះយុទ្ធសាស្ត្រនេះ យើងនឹងខិតខំប្រឹងប្រែងរួមគ្នាដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំ។ ប្រការនេះត្រូវប្រើជាកម្លាំងជំរុញមួយនៅក្នុងការបញ្ជ្រាប

យេនឌ័រ ២០០៦-២០១០ ដោយចាត់ទុកជាឧបករណ៍ក្នុងការរៀបចំឡើងវិញ និងការផ្លាស់ប្តូរឥរិយាបថ និងតម្លៃសង្គមដែលជះឥទ្ធិពលមិនល្អដល់ការអប់រំកុមារី និងសមភាពយេនឌ័រ ។ ការអនុវត្តយុទ្ធសាស្ត្រនេះតម្រូវឱ្យមានឆន្ទៈនយោបាយរឹងមាំ ។

**យុទ្ធសាស្ត្រទី ២ :** ឈរលើទស្សនៈនៃការបង្កើតបរិស្ថានអនុគ្រោះទាំងនៅក្នុង និងក្រៅក្រសួងអប់រំ យុវជន និង កីឡា យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នឹងខិតខំបណ្តុះឥរិយាបថវិជ្ជមានដើម្បីសម្រេចការអប់រំកុមារី សមភាព និង សមធម៌យេនឌ័រក្នុងចំណោមអ្នកពាក់ព័ន្ធនៅក្នុងវិស័យអប់រំ រួមមានវិស័យឯកជនក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសាធារណជនទូទៅដោយបង្កើនការខិតខំប្រឹងប្រែង កសាងកម្មវិធីដូចជា :

១-បង្កើនការយល់ដឹង និងចំណេះដឹងលើបញ្ហាយេនឌ័រនៅក្នុងការអប់រំក្នុងចំណោមសិស្ស មាតាបិតា អ្នកដឹកនាំឃុំ-សង្កាត់

២-ទាក់ទាញការគាំទ្រសាធារណជនទូទៅអំពីសមភាពនិងសមធម៌យេនឌ័រនៅក្នុងការអប់រំតាមរយៈការប្រាស្រ័យទាក់ទង និងកម្មវិធីគាំទ្រលើកទឹកចិត្តដល់ឥរិយាបថ និងតម្លៃសីលធម៌វិជ្ជមានចំពោះការអប់រំក្មេងស្រី ។

យុទ្ធសាស្ត្រទាំងពីរនេះត្រូវធ្វើឱ្យស៊ីគ្នានឹងការបង្កើតវប្បធម៌សមភាពយេនឌ័រនៅក្នុងសង្គមកម្ពុជា ។ កង្វះខាតបញ្ហានេះត្រូវបានមើលឃើញថាជាឧបសគ្គមួយនៅក្នុងការខិតខំប្រឹងប្រែងថ្នាក់ជាតិដើម្បីបង្កើនសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ ។ យុទ្ធសាស្ត្រទាំងនេះឆ្លើយតបទៅនឹងវត្ថុបំណងនីមួយៗនៃការបញ្ជ្រាបយេនឌ័រ ២០០៦-២០១០ ។

រូបគំនូសទី១ បង្ហាញថាវត្ថុបំណងដែលបានរំពឹងទុកពីការចូលរួមផ្តល់លទ្ធផលរំពឹងទុកមួយគឺការធានាកាប្រមូលក្មេងស្រីឱ្យចូលរៀន និងរៀនឱ្យបានពេញលេញនៅកម្រិតអប់រំមូលដ្ឋាន ។ ផែនការបញ្ជ្រាបយេនឌ័រ ២០០៦-២០១០ ផ្តោតលើ ការប្រមូលក្មេង ស្រីចូលរៀននិងរៀនបានពេញលេញជាចំណុចស្នូល ។ យុទ្ធសាស្ត្រគន្លឹះពីរត្រូវបានរកឃើញដើម្បីធ្វើឱ្យសម្រេចលទ្ធផលរំពឹងទុកនេះ ។យុទ្ធសាស្ត្រជាគន្លឹះទាំងពីរត្រូវបានទទួលយក និងធ្វើបន្តដោយយោងទៅលើសមាសភាគនៅក្នុងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ២០០២-២០០៦។ សមាសភាគថ្មី និងសំខាន់គឺការ កសាងឥរិយាបថ សង្គមវិជ្ជមានចំពោះការអប់រំក្មេងស្រី និងសមភាពយេនឌ័រ ។ សមាសភាគសំខាន់ចុងក្រោយ គឺ ការធានាការ គាំទ្រថ្នាក់ជាតិសម្រាប់ការជំរុញសមភាព យេនឌ័រក្នុងចំណោម អ្នកដឹកនាំ និងសាធារណជនជាពិសេសអ្នកដឹក នាំសហគមន៍ មាតាបិតា និងបុរស ។

**រូបគំនូសទី ១: យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០០៦-២០១០**




ភាពប្រទាក់ក្រឡានៃយុទ្ធសាស្ត្រទាំងនេះមានសកម្មភាពសំខាន់ចំនួន ៥ : ការបង្កើនការយល់ដឹងការកសាងសមត្ថភាព សកម្មភាពវិជ្ជមាន ការតស៊ូមតិ និង ការពិនិត្យតាមដាននិងវាយតម្លៃ ។ ប្រការនេះមានសារសំខាន់ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសលើការវិភាគយេនឌ័រនិងបំណិនពាក់ព័ន្ធដែលត្រូវបញ្ចូលនៅក្នុងយុទ្ធសាស្ត្រ ទាំងពីរខាងលើ ។ ការពិនិត្យតាមដាន និងការវាយតម្លៃលទ្ធផលនៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រត្រូវបានប្រើប្រាស់ ក្នុងក្របខ័ណ្ឌធានាគុណភាពដែលស្ថិតនៅក្នុងដំណើរការរបស់ក្រសួងអប់រំ យុវជន និង កីឡានាពាក់កណ្តាល ឆ្នាំ ២០០៦ ។ ស្តង់ដា និងអាំងឌីកាទ័រគុណភាពបញ្ជ្រាបយេនឌ័រល្អ និង មានប្រសិទ្ធភាពត្រូវបានកសាងឡើងដោយក្រុមគុណភាពអប់រំរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នារួមមានគុណភាពនៃការគាំទ្រថ្នាក់ជាតិ គុណភាពនៃភាពជាអ្នកដឹកនាំ និងបុគ្គលិក គុណភាពនៃការអនុវត្តការ

គ្រប់គ្រង គុណភាពនៃការគាំទ្រផ្នែកថវិកា ឬធនធាន និងគុណភាព ពិនិត្យតាមដាន និងវាយតម្លៃផលប៉ះពាល់យេនឌ័រ ។

ស្តង់ដាទាំងនេះនឹងធ្វើជាមគ្គុទ្ទេសក៏នៅក្នុងការអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រ និងត្រូវបានរំពឹងថាការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំនឹងក្លាយជាបញ្ហាផ្ទៃក្នុងសំខាន់បំផុត។ ប្រការចុងក្រោយនេះគឺកាត់បន្ថយបាន "ការនិយមភស្តុតាង " ឬការបញ្ជ្រាបយេនឌ័រដោយរង់ចាំតែធ្វើតាមការណែនាំនិងការបញ្ជាក់ពីថ្នាក់លើប៉ុណ្ណោះ ។

**គ.សំណើជាគន្លឹះពិសេសនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ ២០០៦-២០១០**

១. កសាងផ្អែកលើផលទទួលបានពីការបញ្ជ្រាបយេនឌ័រ ២០០២-២០០៦ ដើម្បីបំពេញការខ្វះចន្លោះ។

២.រៀបចំឱ្យសមស្របជាមួយនឹងកំណែទ្រទ្រង់អប់រំទូទាំងវិស័យ និង អនុវត្តតាមរយៈក្របខ័ណ្ឌអប់រំសម្រាប់ទាំងអស់គ្នា និងកម្មវិធីបញ្ជ្រាបយេនឌ័រក្រសួងអប់រំ យុវជន និង កីឡា ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីគាំទ្រវិស័យអប់រំមានជាអាទិផែនការកម្មភាពជាអាទិភាពមាន ។

៣.ផ្តោតលើការអនុវត្តគោលនយោបាយ បទបញ្ញត្តិ និងសកម្មភាពវិជ្ជមាននៃការបញ្ជ្រាប យេនឌ័រ ។

៤.បន្តខិតខំប្រឹងប្រែងពីដំបូង ដើម្បីកសាងសមត្ថភាពបច្ចេកទេសនៅថ្នាក់ក្រសួង សាលារៀនជាពិសេសនៅថ្នាក់ខេត្ត-ក្រុង និង ស្រុក-ខណ្ឌ ។

៥.ធានាថាក្មេងស្រីទទួលបានការអប់រំប្រកបដោយគុណភាពល្អដើម្បីធ្វើសកម្មភាពរួមគ្នាសំដៅលើកកម្ពស់គុណភាពបញ្ជ្រាបយេនឌ័រតាមរយៈការអនុវត្តស្តង់ដា និងអាំងឌីកាទ័រគុណភាពនៃការបញ្ជ្រាបយេនឌ័រ ។

៦.ជំរុញការអនុវត្ត និងការដាក់យេនឌ័រជាបញ្ហាស្នូលតាមរយៈការពិនិត្យតាមដាន និងការវាយតម្លៃការបញ្ជ្រាបយេនឌ័រដោយសង្គតិភាព

៧.ទទួលស្គាល់ការខ្វះខាតថវិកាយេនឌ័រនិងខិតខំកៀគរធនធានដើម្បីគាំទ្រកម្មវិធីបញ្ជ្រាបយេនឌ័រ

៨.បង្កើនការយកចិត្តទុកដាក់លើការកសាងឥរិយាបថសង្គមវិជ្ជមានចំពោះការអប់រំក្មេងស្រី និងសមភាពយេនឌ័រ ។

៩.ទទួលស្គាល់ពហុលក្ខណៈធម្មជាតិនៃដំណោះស្រាយបញ្ហាយេនឌ័រនៅក្នុងការអប់រំ និងលើកទឹកចិត្តបណ្តុញការងារ និងភ្នាក់ងារសេដ្ឋកិច្ច ដើម្បីផ្សារ ភ្ជាប់ការអប់រំនឹងការខិតខំកាត់បន្ថយភាពក្រីក្រ ។

១០.ខិតខំកសាង "វប្បធម៌សមភាព" នៅក្នុងសង្គមកម្ពុជា ។

**ឃ.ការឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍ដើម្បីលើកកម្ពស់សមភាពសមធម៌យេនឌ័រក្នុងការអប់រំ**

កំណែទម្រង់វិស័យអប់រំ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធដូចជា សំណង់សាលារៀន កម្មវិធីសម្រាប់សមភាព និងសមធម៌យេនឌ័រក្នុងវិស័យអប់រំ ការផ្តល់អាហារូបករណ៍សម្រាប់សិស្សស្រីដើម្បីបង្កើនការប្រមូលក្មេងស្រីក្រីក្រនៅកម្រិតអប់រំមូលដ្ឋានរាប់បញ្ចូលទាំងជនជាតិភាគតិចនៅតំបន់ជនបទ និងដាច់ស្រយាលឱ្យបានចូលរៀន

ត្រូវបានគាំទ្រនិងឆ្លើយតបពីសំណាក់ដៃគូអភិវឌ្ឍន៍នានា។

**ង.ការគាំទ្រផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រ**

ការអនុវត្តផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រតម្រូវឱ្យមានទម្រង់ផ្សេងៗគ្នានៃការគាំទ្រថ្នាក់ជាតិ ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងសាលារៀន ។

**១.ការគាំទ្រសីលធម៌ នយោបាយ និងការប្តេជ្ញាចិត្តក្នុងភាពជាអ្នកដឹកនាំ**

ការប្តេជ្ញាចិត្តក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ខ្ពស់បំផុតគឺជាការសំខាន់សម្រាប់ធានាការបន្តនូវអត្ថប្រយោជន៍ ស្របនឹងអាទិភាព ការចែករំលែកធនធាន និងជំរុញសកម្មភាពអនុវត្តដើម្បីបញ្រ្ជាបយេនឌ័រក្នុងវិស័យអប់រំ ។ ប្រការនេះរាប់បញ្ចូលទាំងការគាំទ្ររបស់អ្នកដឹកនាំសហគមន៍ មាតាបិតា ជាពិសេសបុរសដើម្បីកសាងបរិស្ថានវិជ្ជមានសម្រាប់អប់រំកុមារីនិង សមភាពយេនឌ័រ ។ បច្ចុប្បន្ននេះ ការបញ្រ្ជាបយេនឌ័រនៅក្នុងវិស័យអប់រំមានការគាំទ្រយ៉ាងសំខាន់ពីថ្នាក់ដឹកនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។ ការខិតខំប្រឹងប្រែងដ៏ធំធេង គឺការប្រែក្លាយការប្តេជ្ញាចិត្តឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងដើម្បីឈានទៅសម្រេចលទ្ធផលរំពឹងទុក ។

**២.ធនធាន**

ការបញ្រ្ជាបយេនឌ័រតម្រូវឱ្យមានការចូលរួមពីមន្ត្រីអប់រំដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងការវិភាគយេនឌ័រ និងបំណិនពាក់ព័ន្ធ។ មន្ត្រីទាំងនោះអាចធ្វើសកម្មភាពដូចជា អ្នកតស៊ូមតិ ជំនាញបច្ចេកទេស និងជាអ្នកប្រឹក្សា ដើម្បីដឹកនាំដំណើរការនៅនឹងកន្លែងជាពិសេសថ្នាក់ ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ។ ធនធានបណ្តុះបណ្តាល ឧបករណ៍ ឯកសារ និងសេចក្តីណែនាំសម្រាប់ការបញ្រ្ជាបយេនឌ័រចាំបាច់ត្រូវកសាង និងត្រូវ បានផ្សព្វផ្សាយឱ្យបានឆាប់រហ័ស។ ការបណ្តុះបណ្តាលពីការប្រើប្រាស់ឯកសារបញ្រ្ជាបយេនឌ័រឱ្យបានសមស្រប និងការតាមដានការប្រើប្រាស់ជាផ្នែកមួយនៃកម្មវិធីពិនិត្យតាមដាន ។

**៣.ថវិកា**

ការបណ្តុះបណ្តាលមន្ត្រីអប់រំ និងការផ្សព្វផ្សាយជាផ្លូវការនៃសកម្មភាពបញ្រ្ជាបយេនឌ័រតម្រូវឱ្យមានធនធានសមស្រប ដើម្បីធានាប្រសិទ្ធភាព ។ ដោយសារធនធានទាំងនោះជាធនធានកម្រ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវស្វែងរកប្រភពថវិកាដើម្បីទ្រទ្រង់កម្មវិធីបញ្រ្ជាបយេនឌ័រ ។ ប្រការនេះតម្រូវឱ្យមានការផ្សារភ្ជាប់ នឹងបណ្តាញការងារយ៉ាងសកម្មជាមួយដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពលទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ។

**៤.ភាពជាដៃគូ**

ការខិតខំប្រឹងប្រែងដើម្បីកសាងឥរិយាបថវិជ្ជមាន និងបរិស្ថានដែលធ្វើសម្រាប់អប់រំកុមារី និងសមភាពយេនឌ័រតម្រូវឱ្យមានការផ្សារភ្ជាប់ជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ឧទាហរណ៍ដូចជាការផ្តល់អាហារូបករណ៍ដល់សិស្សស្រីក្រីក្រ។ នៅកម្រិតសហគមន៍ភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលត្រូវបន្ថែមការតស៊ូមតិ និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលអាចគាំទ្រសកម្មភាពជាវិជ្ជមាន។ ភាពជាដៃគូសំខាន់មិនមែនមានតែនៅក្នុងការគាំទ្រប៉ុណ្ណោះទេ ប៉ុន្តែអាចធានានិរន្តរភាពផលទទួលបាននៃការបញ្រ្ជាបយេនឌ័រនៅរយៈពេល

រៀន។ ក្រសួងអប់រំ យុវជន និង កីឡា ត្រូវផ្សារភ្ជាប់ការងារទំនាក់ទំនងជាមួយគ្រប់ភ្នាក់ងាររួមមានក្រសួង ស្ថាប័ននៅក្នុងរាជរដ្ឋាភិបាល និង វិស័យឯកជនដែលបានជួយលើកទឹកចិត្តលក្ខខ័ណ្ឌសេដ្ឋកិច្ចគ្រួសារក្រីក្រ។ ការធ្វើឱ្យសេដ្ឋកិច្ចគ្រួសារក្រីក្របានប្រសើរឡើងជាវិធីមួយជំរុញឱ្យគាត់បញ្ជូនកូនទៅរៀន ជាពិសេសគឺកូនស្រី ។

## ច.ឧបសគ្គ និងការសន្មតនៃផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ ២០០៦-២០១០

**ការសន្មត**

១. ការបន្តអនុវត្តកំណែទម្រង់អប់រំទូទាំងវិស័យដូចជាការពង្រីកសាលា និងថ្នាក់រៀន ការពង្រាយគ្រូនៅតាមតំបន់ដាច់ស្រយាល និងតំបន់ជនបទដែលពុំទាន់សម្រេចបានតាមគោលដៅ ។

២. ការបន្តការប្តេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និង កីឡា នៅក្នុងការអនុវត្តគោលនយោបាយយេនឌ័រ ។

៣. ភាពដែលអាចរកបានអ្នកផ្តល់ជំនួយនិងអ្នកគាំទ្រដែលផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់កម្មវិធីយេនឌ័ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

៤. បណ្តាញការងារពហុវិស័យរបស់អ្នកជាដៃគូ និងអ្នកគាំទ្រយេនឌ័រនៅក្នុងវិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល និងរាជរដ្ឋាភិបាលនឹងបន្តគាំទ្រកម្មវិធីយេនឌ័រ និងសកម្មភាពជាវិជ្ជមានរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

៥. ការបង្កើនសមត្ថភាពថ្នាក់ជាតិសម្រាប់ការបញ្ជ្រាបយេនឌ័រ និងការផ្លាស់ប្តូរឥរិយាបថ និងតម្លៃសីលធម៌ដើម្បីជួយធានានិរន្តរភាពនៃការអនុវត្តកម្មវិធី និងគោលនយោបាយយេនឌ័រ ។

**ឧបសគ្គ**

១. ការផ្លាស់ប្តូររាជរដ្ឋាភិបាល និង អាណត្តិនយោបាយធ្វើឱ្យអាទិភាពចុះខ្សោយសម្រាប់កម្មវិធី និង គោលនយោបាយយេនឌ័រ ។

២. ការគាំទ្រពីដៃគូអភិវឌ្ឍន៍ ប្រភពមូលនិធិថយចុះ និង/ឬ លុបចោលការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងប្រភពថវិកាផ្សេងៗ ។

## ឆ. ក្របខ័ណ្ឌសមហេតុផលនៃកម្មវិធីបញ្ជ្រាបយេនឌ័រ ២០០៦_២០១០

**លទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រ**

**នៅឆ្នាំ ២០១៥ សិស្សស្រីនឹងបានចូលរៀនស្មើគ្នានិងពេញលេញនៅកម្រិតអប់រំមូលដ្ឋានប្រកបដោយគុណភាពនៅកម្ពុជា**

**សូចនាករ**

១. ការបន្ថយគម្លាតយេនឌ័រនៅតំបន់ជនបទ និងដាច់ស្រយាល

- ពង្រីកមត្តេយ្យសិក្សានៅតំបន់ដាច់ស្រយាល
- អត្រាពិតនៃការសិក្សា នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតំបន់ដាច់ស្រយាល

២. ការបង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សារបស់កុមារី

៣. ការកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សស្រីពិសេសនៅកម្រិតអប់រំមូលដ្ឋាន

៤. បង្កើនអត្រាឆ្លងភូមិសិក្សានៅកម្រិតមធ្យមសិក្សា

៥. បង្កើនអត្រាគង់វង្សនៅថ្នាក់ទី ៦ របស់សិស្សស្រីនៅបឋមសិក្សា

៦. ការបង្កើនអត្រាពិតនៃការសិក្សានៅវិទ្យាល័យ និងឧត្តមសិក្សា

៧. ការអនុវត្តស្តង់ដានិងអាំងឌីកាទ័រគុណភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ ។

**លទ្ធផលដំបូងទី១**

**នៅឆ្នាំ ២០១០ ការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងនិងការផ្តល់សេវាអប់រំមាន ២០-២៥%**

| លទ្ធផលដំបូង | សូចនាករ | ចំណុចចាប់ផ្តើម ២០០៥ | ចំណុចដៅ ២០១០ | មធ្យោបាយផ្ទៀងផ្ទាត់ | សកម្មភាពគន្លឹះ |
|---|---|---|---|---|---|
| **លទ្ធផលដំបូង ១.**<br>• ស្ត្រីច្រើនក្លាយជាមន្ត្រីគ្រប់គ្រងអប់រំ អ្នកធ្វើផែនការ និងគោលនយោបាយ ។<br><br>**លទ្ធផលដំបូង ១.១**<br>• ស្ត្រីជាច្រើនបានក្លាយជាអ្នកគ្រប់គ្រង អ្នកកសាងផែនការ និងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ។ | ១.បង្កើនសមាមាត្រនៃចំនួនស្ត្រីនៅក្នុងការងារគ្រប់គ្រងនិងធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់កណ្តាល ខេត្ត-ក្រុង និង ស្រុក-ខណ្ឌ ។<br>២.បង្កើនសមាមាត្រនៃចំនួននាយិកា និងនាយិការងសាលារៀន ។<br>៣.បង្កើនសមាមាត្រអ្នកគ្រូ៤០%<br>៤.ចំនួន និងសមាមាត្រស្ត្រីដែលបានបណ្តុះបណ្តាលលើការងារគ្រប់គ្រងការងារផែនការ និងការកសាងគោលនយោបាយ ។<br>៥.ចំនួន និងសមាមាត្រនាយិកា នាយិការង ប្រធាន-អនុប្រធាន | • ស្ត្រី ៣-៦% នៅក្នុងការគ្រប់គ្រងថ្នាក់កណ្តាលរបស់ក្រសួងអប់រំ យុវជន និង កីឡា ។<br>• ស្ត្រី ៤-២២%នៅថ្នាក់-ខេត្ត-ក្រុង ។<br>• ស្ត្រី២-៦% នៅថ្នាក់ការិយាល័យស្រុក-ខណ្ឌ។<br>• ស្ត្រី៧-៩% ជានាយិកាសាលា ឬនាយិការង | ២០-២៥%<br>-<br>២៥%<br>២៥%<br>២០-២៥%<br>-<br>៥០% | - ស្ថិតិ EMIS ឬពីនាយកដ្ឋានបុគ្គលិកស្តីពីការចូលរួម របស់ស្ត្រីក្នុងតួនាទីគ្រប់គ្រងនៅថ្នាក់កណ្តាលថ្នាក់ ខេត្ត-ក្រុង ស្រុក-ខណ្ឌ និង សាលារៀន ។<br>- របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃ ។<br>- របាយការណ៍របស់ក្រុមការងារយេនឌ័រក្រសួងអយក ។<br>- របាយកាណ៍ប្រចាំឆ្នាំរបស់កម្មវិធីគាំទ្រវិស័យអប់រំស្តីពីការបញ្ជ្រាបយេនឌ័រ ។ | **បង្កើនការយល់ដឹង**<br>• បង្កើការយល់ដឹងយេនឌ័រលើការងារអប់រំក្នុងចំណោមមន្ត្រីអប់រំរបស់ក្រសួង អប់រំ យុវជន និងកីឡា ជាពិសេស ថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងសាលារៀនរួមមាននាយក សាលា និងគ្រូបង្រៀន ។<br>**កសាងសមត្ថភាព**<br>•កសាងកម្មវិធីកសាងសមត្ថភាពសម្រាប់ស្ត្រីជាអ្នកគ្រប់គ្រង អ្នកធ្វើផែនការ និងអ្នកកសាងគោលនយោបាយតាមរយៈការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា អាហារូបករណ៍ក្នុង និងក្រៅប្រទេស ។<br>• រៀបចំកម្មវិធីសិក្ខាសាលាដើម្បីបណ្តុះ |

| | | | | | |
|---|---|---|---|---|---|
| | ការិយាល័យដែលបានបណ្តុះបណ្តាលលើការងារគ្រប់គ្រង ទទួលបានអាហារូបករណ៍ក្នុង និងក្រៅប្រទេស ។<br>៦.ចំនួន និងសមាមាត្រ អ្នកគ្រប់គ្រង (ដូចជានាយកដ្ឋានជំនាញប្រធាន និងអនុប្រធានការិយាល័យនៅថ្នាក់កណ្តាល មន្ទីរអប់រំ យុវជន និង កីឡា មានប្រធាន-អនុប្រធានមន្ទីរ និងការិយាល័យជំនាញនៅមន្ទីរអប់រំ យុវជន និង កីឡា និងការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខណ្ឌ សាលារៀនត្រូវបានបណ្តុះបណ្តាលពីយេនឌ័រ ។ | | | -របាយការណ៍វាយតម្លៃពាក់កណ្តាលទសវត្សរ៍របស់ការអប់រំសម្រាប់ទាំងអស់គ្នា ។ | បណ្តាល ជំនាញលើការវិភាគយេនឌ័រ ការកសាងផែនការពិនិត្យតាមដាន និងវាយតម្លៃដល់មន្ត្រីអប់រំថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងសាលារៀន ។<br>• ពង្រឹងយន្តការគណៈកម្មការយេនឌ័រថ្នាក់កណ្តាល ខេត្ត ក្រុង ស្រុក ខណ្ឌ សាលារៀនក្នុងការគាំទ្រឧបត្ថម្ភដល់ស្ត្រីឱ្យបានច្រើនដើម្បីចូលរួមជាអ្នកគ្រប់គ្រង អ្នកធ្វើផែនការ កសាងគោលនយោបាយដោយផ្តល់ទីប្រឹក្សាបច្ចេកទេសការបណ្តុះបណ្តាល ការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការពិនិត្យតាមដាន និងវាយតម្លៃនៅថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខណ្ឌ សាលារៀន ។ |
| **លទ្ធផលដំបូង ១.២**<br>•អ្នកគ្រូមានច្រើន ជាពិសេសនៅតំបន់ជនបទ និង តំបន់ | ១.បង្កើនចំនួនសមាមាត្រគ្រូស្រីនៅគ្រប់កម្រិត ពិសេសនៅតំបន់ជនបទ និង ដាច់ស្រយាល ។ | ២៦% | ៤០% | •ស្ថិតិយេនឌ័រនៅតាមសាលារៀន និងគ្រប់កម្រិតរាប់បញ្ចូលទាំង | **<u>សកម្មភាពវិជ្ជមាន</u>**<br>•រៀបចំនិងអនុវត្តគោលការណ៍សម្រាប់ការជ្រើសរើសនិងដំឡើងឋានៈតួនាទី |

| | | | | | |
|---|---|---|---|---|---|
| ដាច់ស្រយាល ។ | ២/មានសមមាត្រចំនួនស្ត្រីនៅក្នុងការបណ្តុះបណ្តាលបំណិនផ្នែកបច្ចេកទេស និងយេនឌ័រ<br>៣/មានសមាមាត្រចំនួនស្ត្រីនៅក្នុងការទទួលបានអាហារូបករណ៍ក្នុង និងក្រៅប្រទេស | ៥០%<br>៥០%(ក្នុង PAP ទីមួយ១) | | ការបណ្តុះបណ្តាល និងអាហារូបករណ៍ របាយការណ៍ពីវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាបណ្តុះបណ្តាលយេនឌ័រ របាយការណ៍ពីកម្មវិធីអាហារូបករណ៍ ។ | ស្ត្រី ។<br>**ឧបត្ថម្ភគាំទ្រ**<br>•កសាងយុទ្ធសាស្ត្រគាំទ្រពីអ្នកពាក់ព័ន្ធក្នុងការតែងតាំងស្ត្រីឱ្យមានតួនាទីសំខាន់នៅក្រសួង អប់រំ យុវជន និង កីឡា ។<br>**ពិនិត្យតាមដាន**<br>•ពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលនៃសកម្មភាពវិជ្ជមានលើចំណេះដឹង និងការ កសាងសមត្ថភាព ។<br>**បង្កើនការយល់ដឹង**<br>•បណ្តុះបណ្តាលការយល់ដឹងយេនឌ័រតាមរយៈសិក្ខាសាលាដល់មន្ត្រីអប់រំនៅក្រសួងអប់រំ យុវជន និង កីឡា មន្ទីរ អយក ខេត្ត-ក្រុង ការិ. អយកស្រុក-ខណ្ឌ និងសាលារៀន ។<br>•បណ្តុះបណ្តាលយេនឌ័រជាពិសេសដល់មន្ទីរ អប់រំ យុវជន និង កីឡាខេត្ត-ក្រុង ការិ. អប់រំ យុវជន និង កីឡា ស្រុក-ខណ្ឌ ដើម្បីឆ្ពោះទៅរកការអនុវត្តព្រ័ន្ធ |

| | | | | | |
|---|---|---|---|---|---|
| | | | | | វិមជ្ឈការ ។<br><br>**កសាងសមត្ថភាព**<br>•បង្កើនសមត្ថភាព គ្រូបង្រៀនជាពិសេសអ្នកគ្រូក្នុងការគាំទ្រសមភាពយេនឌ័រ និងការអប់រំកុមារី ។<br>•បង្កើនសមត្ថភាពក្នុងការពិនិត្យតាមដាននិងវាយតម្លៃនៅថ្នាក់កណ្ដាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន ។<br>•លើកទឹកចិត្តអ្នកគ្រូនៅតំបន់ដាច់ស្រយាល និងតំបន់ជនបទ។<br>**<u>ការពិនិត្យតាមដាន និងវាយតម្លៃ</u>**<br>•ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃការបញ្ជ្រាបយេនឌ័រនៅតាមសាលារៀនក្នុងប្រព័ន្ធ។ ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសកម្មភាពវិជ្ជមាន និងការកសាងសមត្ថភាពដែលបានលើកឡើង ។ |

លទ្ធផលដំបូងទី២

**នៅឆ្នាំ ២០១០ ឥរិយាបថវិជ្ជមានចំពោះការអប់រំកុមារី និងសមភាពយេនឌ័រនឹងកើនឡើងក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យអប់រំ និង សាធារណជនទូទៅ**

| លទ្ធផលដំបូង | សូចនាករ | ចំណុចចាប់ផ្តើម ២០០៥ | ចំណុចដៅ ២០១០ | មធ្យោបាយផ្ទៀងផ្ទាត់ | សកម្មភាព |
|---|---|---|---|---|---|
